**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ...២៤... អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## បុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣១ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីក្ស័យធន
- បានឃើញអនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងធានាការគ្រប់គ្រងបុននីតិសម្បទា និងការជម្រះបញ្ជីក្នុងវិស័យមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីបែបបទ នីតិវិធីក្នុងការធ្វើបុននីតិសម្បទា និងការជម្រះបញ្ជី ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួលស្គាល់ពីគណៈកម្មការមូលបត្រកម្ពុជា(**គ.ម.ក.**) និងបុគ្គលបោះផ្សាយលក់មូលបត្រជាសាធារណៈ ដែលមាន ឬអាចមានបញ្ហាផ្នែកហិរញ្ញវត្ថុដើម្បី÷

- បង្ការពីការក្ស័យធន តាមរយៈការធ្វើបុននីតិសម្បទា
- បង្កើន និងរក្សាទំនុកចិត្តក្នុងទីផ្សារមូលបត្រ តាមរយៈការការពារសុវត្ថិភាពទ្រព្យសកម្មរបស់អ្នកវិនិយោគ ដោយការជម្រះបញ្ជីឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព
- ផ្តល់ក្របខ័ណ្ឌគតិយុត្តឱ្យ **គ.ម.ក.** ធ្វើសហប្រតិបត្តិការជាមួយបញ្ញត្តិករពាក់ព័ន្ធ ចំពោះបុគ្គលបោះផ្សាយដែលមានប្រតិបត្តិការអាជីវកម្មស្ថិតក្រោមបញ្ញត្តិករដាច់ដោយឡែក ដើម្បីធ្វើបុននីតិសម្បទា និងជម្រះបញ្ជី។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬការទទួល ស្គាល់ពី **គ.ម.ក.** និងបុគ្គលបោះផ្សាយលក់មូលបត្រជាសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២
## ការបើកនីតិវិធីបុននីតិសម្បទា

**មាត្រា៥ .-**

អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចំនួនច្រើន ឬបុគ្គលផ្សេងទៀតដូចមានចែងនៅក្នុង លក្ខន្តិកៈរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ត្រូវស្នើសុំទៅ **គ.ម.ក.** ដើម្បីបើកនីតិវិធីបុននីតិសម្បទា ក្នុង ករណីដែលក្រុមហ៊ុន ឬបុគ្គលបោះផ្សាយមាន ឬអាចមានបញ្ហាហិរញ្ញវត្ថុ ដូចខាងក្រោម÷

ក- ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយអាចស្ថិតក្នុងស្ថានភាពមិនអាចមានលទ្ធភាពក្នុងការបំពេញតាម លក្ខខណ្ឌមូលធនអប្បបរមាដូចកំណត់ដោយ **គ.ម.ក.**។

ខ- ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយពិនិត្យឃើញថាហានិភ័យដែលមានចែងក្នុងផែនការគ្រប់គ្រងហានិភ័យ ដែលតម្រូវដោយ **គ.ម.ក.** ឬហានិភ័យផ្សេងទៀត អាចកើតឡើងជាក់ស្តែងចំពោះក្រុមហ៊ុន ឬបុគ្គលបោះ-

ផ្សាយ ឬក្រុមហ៊ុន ឬបុគ្គលបោះផ្សាយអាចប្រឈមនឹងហានិភ័យដែលបណ្តាលឱ្យក្រុមហ៊ុន ឬបុគ្គលបោះផ្សាយត្រូវជួបប្រទះ ឬអាចជួបប្រទះបញ្ហាផ្នែកហិរញ្ញវត្ថុ។

គ- ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយពិនិត្យឃើញថា ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយអាចនឹងក្លាយជាអសាធនីយ។

ឃ- ស្ថានភាពផ្សេងទៀតដែលកំណត់ដោយ **គ.ម.ភ.**។

**មាត្រា៦ .-**

សំណើសុំបើកនីតិវិធីបុនឌីតិសម្បទា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយបុគ្គលដាក់ពាក្យស្នើសុំ ព្រមទាំងត្រូវបញ្ជាក់នូវព័ត៌មានដូចខាងក្រោម÷

ក- នាមករណ៍ និងអាសយដ្ឋានរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ

ខ- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានអ្នកស្នើសុំ

គ- មូលហេតុដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ ព្រមទាំងភ្ជាប់មកជាមួយនូវសេចក្តីបញ្ជាក់ភស្តុតាង និងឯកសារពាក់ព័ន្ធផ្សេងៗតាមការចាំបាច់។

**មាត្រា៧ .-**

ករណី **គ.ម.ភ.** យល់ឃើញថាក្រុមហ៊ុន ឬបុគ្គលបោះផ្សាយមាន ឬអាចជួបប្រទះបញ្ហាហិរញ្ញវត្ថុដូចមានកំណត់ក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ អគ្គនាយកនៃ **គ.ម.ភ.** អាចប្រកាសបើកនីតិវិធីបុនឌីតិសម្បទាដោយផ្ទាល់ ឬតាមការស្នើសុំរបស់អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចំនួនច្រើន ឬបុគ្គលផ្សេងទៀតដូចមានចែងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ។

**មាត្រា៨ .-**

អគ្គនាយកនៃ **គ.ម.ភ.** អាចតែងតាំងអភិបាលបណ្តោះអាសន្នដោយផ្ទាល់ ឬតាមរយៈសំណើរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ដើម្បីអនុវត្តនីតិវិធីបុនឌីតិសម្បទា។

អភិបាលបណ្តោះអាសន្នត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះអភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជីដែលទទួលស្គាល់ពី **គ.ម.ភ.**។ លក្ខខណ្ឌគុណវុឌ្ឍិ និងក្រមសីលធម៌វិជ្ជាជីវៈរបស់អភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជី ត្រូវកំណត់ដោយ **គ.ម.ភ.**។

ចំពោះក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ការតែងតាំងអភិបាលបណ្តោះអាសន្ន ត្រូវសហការជាមួយបញ្ញត្តិករពាក់ព័ន្ធ សម្រាប់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដែលមានប្រតិបត្តិការអាជីវកម្មស្ថិតក្រោមបញ្ញត្តិករដាច់ដោយឡែក។

**មាត្រា៩ .-**

អភិបាលបណ្តោះអាសន្នមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

១- រៀបចំផែនការបុនឌីតិសម្បទា

២- អនុវត្តផែនការបុនឌីតិសម្បទា

៣- រៀបចំរបាយការណ៍វាយតម្លៃថាក្រុមហ៊ុន ឬបុគ្គលបោះផ្សាយសាធនីយ អាចសាធនីយ ឬអសាធនីយ។

អភិបាលបណ្តោះអាសន្នត្រូវបំពេញតួនាទី និងភារកិច្ចក្នុងរយៈពេល ៣(បី) ខែ ហើយក្នុងករណីចាំបាច់អាចត្រូវបានពន្យារពេល ៣(បី) ខែទៀត ដោយមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

**មាត្រា១០ .-**

តាមការណែនាំ និងការតាមដានត្រួតពិនិត្យរបស់អគ្គនាយកនៃ **គ.ម.ក.** អភិបាលបណ្តោះអាសន្នមានសិទ្ធិអំណាចដូចខាងក្រោម÷

១- បញ្ឈប់ និង/ឬដាក់ជំនួសនូវបុគ្គលិកជាន់ខ្ពស់ និងអភិបាល និងត្រូវយកប្រាក់ ឬលាភការដែលទទួលបានលើសពីទំហំការងារពីបុគ្គលទាំងនោះមកវិញ។

២- ចាត់វិធានការគ្រប់គ្រង និងចាត់ចែងក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ដើម្បីសង្គ្រោះធុរកិច្ចក្រុមហ៊ុន ឬបុគ្គលបោះផ្សាយទាំងមូល ឬមួយផ្នែក សំដៅធ្វើឱ្យក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ មានដំណើរការអាជីវកម្មជាប្រក្រតីឡើងវិញប្រកបដោយនិរន្តរភាព។

៣- ដាក់ឱ្យធ្វើវាល់ប្រតិបត្តិការរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយតាមគ្រប់រូបភាព រួមបញ្ចូលទាំងការបញ្ចប់កិច្ចសន្យា ការបន្តកិច្ចសន្យា ការផ្ទេរកិច្ចសន្យា ការទិញ ឬលក់ទ្រព្យសម្បត្តិ ការគ្រប់គ្រងបំណុល ការកាត់បន្ថយប្រតិបត្តិការធុរកិច្ច និងចាត់វិធានការចាំបាច់នានា ដើម្បីរៀបចំក្រុមហ៊ុន ឬបុគ្គលបោះផ្សាយឡើងវិញ។

៤- ធានានិរន្តរភាពសេវាកម្ម និងមុខងារចាំបាច់ ដោយតម្រូវឱ្យក្រុមហ៊ុនផ្សេងទៀត ដែលស្ថិតក្នុងសម្ព័ន្ធក្រុមហ៊ុនតែមួយ ឬក្រុមហ៊ុនពាក់ព័ន្ធផ្សេងទៀត បន្តផ្តល់សេវាកម្មមានស្រាប់ទៅឱ្យក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដែលកំពុងស្ថិតនៅក្នុងនីតិវិធីបុននីតិសម្បទា ឬធានាថាក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដែលកំពុងស្ថិតក្នុងនីតិវិធីបុននីតិសម្បទា អាចផ្តល់សេវាកម្មជាបណ្តោះអាសន្ន ឬធ្វើលទ្ធកម្មសេវាកម្មចាំបាច់ផ្សេងទៀតពីបុគ្គលដែលមិនធ្លាប់មានទំនាក់ទំនងអាជីវកម្មជាមួយកន្លងមក។

៥- រំលាយក្រុមហ៊ុនបញ្ចូលគ្នា ទិញ លក់ប្រតិបត្តិការធុរកិច្ចជាសារវន្ត បំពេញដើមទុន ឬចាត់វិធានការផ្សេងទៀត ដើម្បីរៀបចំក្រុមហ៊ុន ឬបុគ្គលបោះផ្សាយឡើងវិញ និងចាត់ចែងធុរកិច្ច ឬទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ។

៦- ផ្ទេរ ឬលក់ទ្រព្យសកម្ម និងទ្រព្យអកម្ម រួមទាំងសិទ្ធិ និងកាតព្វកិច្ចស្របច្បាប់ផ្សេងទៀត ដោយមិនតម្រូវឱ្យមានការយល់ព្រមជាមុនពីភាគីពាក់ព័ន្ធណាមួយឡើយ។

៧- ពន្យារពេលជាបណ្តោះអាសន្ននូវការអនុវត្តសិទ្ធិបញ្ចប់កិច្ចសន្យា ឬកិច្ចព្រមព្រៀងផ្សេងៗ ដែលអាចកើតឡើងដោយសារក្រុមហ៊ុន ឬបុគ្គលបោះផ្សាយកំពុងស្ថិតក្នុងនីតិវិធីបុននីតិសម្បទា ឬដោយសារការប្រើប្រាស់សិទ្ធិអំណាចក្នុងនីតិវិធីបុននីតិសម្បទា។

៨- កំណត់អំឡុងពេលផ្អាកការសងបំណុលទៅអតិថិជន និងម្ចាស់បំណុលគ្មានកិច្ចធានា លើកលែងតែការទូទាត់សង និងការផ្ទេរទ្រព្យសម្បត្តិទៅសមភាគីកណ្តាល ដែលការទូទាត់ទាំងនោះកំពុងស្ថិតក្នុងប្រព័ន្ធផាត់ទាត់ និងទូទាត់ និងផ្អាកម្ចាស់បំណុលក្នុងការទាមទារទ្រព្យសកម្មពីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ និងពីកិច្ចព្រមព្រៀងប្រាតិភោគនានា។

៩- ករណីចាំបាច់ ត្រូវផ្អាក ឬកាត់បន្ថយប្រតិបត្តិការធុរកិច្ចមួយផ្នែករបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ និងទូទាត់សងបំណុលទៅឱ្យម្ចាស់បំណុលបុរិមាមានកិច្ចធានា។

១០- ប្ដឹងទាមទារបំណុលពីកូនបំណុលរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ។

១១- ប្រមូលព័ត៌មាន ពិនិត្យ និងតម្រូវឱ្យផ្ដល់នូវរាល់បញ្ជី និងកំណត់ត្រា ព្រមទាំងឯកសារពាក់ព័ន្ធទាំងអស់របស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ។

១២- អាចមានសិទ្ធិអំណាចផ្សេងទៀតតាមការកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី៣
## អានុភាពនៃការបើកនីតិវិធីបុនីតិសម្បទា
### ផ្នែកទី១
### ដំណើរការនៃការធ្វើបុនីតិសម្បទា

**មាត្រា១១ ..**

អភិបាលបណ្ដោះអាសន្ន ត្រូវរៀបចំផែនការបុនីតិសម្បទា ដោយត្រូវចែងអំពីលទ្ធភាពទទួលបានជោគជ័យនៃយុទ្ធសាស្ត្របុនីតិសម្បទាក្នុងបរិបទនៃមុខងារ និងតួនាទី ប្រតិបត្តិការ រចនាសម្ព័ន្ធ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ។

ផែនការបុនីតិសម្បទាត្រូវចែងផងដែរអំពី÷

១- ព័ត៌មានពិស្ដាររបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ រួមទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។

២- ឈ្មោះ និងអាសយដ្ឋានទំនាក់ទំនងរបស់ម្ចាស់បំណុល។

៣- បញ្ជាក់ថាតើសិទ្ធិលើបំណុលនោះជាសិទ្ធិលើបំណុលមានកិច្ចធានា ឬមិនមានកិច្ចធានា និងឥណប្រតិទាននៃសិទ្ធិលើបំណុល។

៤- ព័ត៌មានផ្សេងទៀតតាមការចាំបាច់ និង/ឬតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

អភិបាលបណ្ដោះអាសន្ន ត្រូវរៀបចំផែនការបុនីតិសម្បទាឱ្យបានចប់សព្វគ្រប់ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទតែងតាំង ហើយត្រូវដាក់ជូន **គ.ម.ក.** និងក្រុមហ៊ុន ឬបុគ្គលបោះផ្សាយភ្លាម។

ករណីអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា ផែនការបុនីតិសម្បទាមិនមានលក្ខណៈសមស្រប អគ្គនាយកនៃ **គ.ម.ក.** អាចណែនាំអភិបាលបណ្ដោះអាសន្នឱ្យពិនិត្យ និងរៀបចំឡើងវិញ ឬតែងតាំងអភិបាលបណ្ដោះអាសន្នថ្មីជំនួសឱ្យបានឆាប់បំផុត។

**មាត្រា១២ ..**

ករណីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយកំពុងស្ថិតនៅក្នុងនីតិវិធីបុនីតិសម្បទា រាល់ឯកសារទាំងអស់ដែលចេញដោយ ឬចេញក្នុងនាមក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ អភិបាលបណ្ដោះអាសន្ន ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ត្រូវចែងនូវឈ្មោះ និងតួនាទីជាអភិបាលបណ្ដោះអាសន្ន ព្រមទាំងសេចក្ដីបញ្ជាក់ដូចខាងក្រោម÷

១- រាល់កិច្ចការធុរកិច្ច និងទ្រព្យសម្បត្តិទាំងអស់របស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ កំពុងស្ថិតនៅក្រោមការគ្រប់គ្រង និងចាត់ចែងដោយអភិបាលបណ្ដោះអាសន្ន។

២- ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយកំពុងស្ថិតនៅក្រោមការណែនាំរបស់ **គ.ម.ក.** ឱ្យមានការផ្អាកសងបំណុលជាបណ្ដោះអាសន្ន ប្រសិនបើមាន។

ដើម្បីការពារផលប្រយោជន៍របស់អ្នកវិនិយោគ និងដើម្បីធានានូវទំនុកចិត្តទីផ្សារ អគ្គនាយកនៃ **គ.ម.ក.** អាចណែនាំឱ្យក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ មិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៣.-**

លើកលែងតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ក្នុងអំឡុងពេលអនុវត្តតាមការណែនាំឱ្យមានការផ្អាកសងបំណុលជាបណ្ដោះអាសន្ន ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដែលកំពុងស្ថិតនៅក្រោមនីតិវិធីបុនរីតិសម្បទា មិនត្រូវបានទទួលរង៖

១- ការរំលាយ ឬការជម្រះបញ្ជីដោយសេចក្ដីសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

២- ការជម្រះបញ្ជីតាមសេចក្ដីសម្រេចណាមួយ។

៣- ការចាត់វិធានការដែលបង្កើត ឬបង្ខំឱ្យអនុវត្តឯកសិទ្ធិ ឬប្រាតិភោគណាមួយចំពោះទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ដោយបុគ្គលណាមួយ។

៤- ចំណាត់ការផ្លូវច្បាប់ណាមួយ រួមទាំងការបើកសំណុំរឿងក្ស័យធន ឬការអនុវត្តសេចក្ដីសម្រេចផ្សេងៗ ឬការរឹបអូសទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ។ ចំពោះចំណាត់ការផ្លូវច្បាប់របស់តុលាការ អភិបាលបណ្ដោះអាសន្នត្រូវស្នើសុំទៅតុលាការឱ្យព្យួរបណ្ដឹង ឬផ្អាកការអនុវត្តសេចក្ដីសម្រេចនោះរហូតដល់ការបញ្ចប់នីតិវិធីបុនរីតិសម្បទា និងការជម្រះបញ្ជី។

ក្នុងករណីដែល **គ.ម.ក.** ណែនាំឱ្យផ្អាកសងបំណុលជាបណ្ដោះអាសន្ន សេចក្ដីណែនាំនេះត្រូវផ្សព្វផ្សាយជាសាធារណៈ លើកលែងតែអគ្គនាយកនៃ **គ.ម.ក.** យល់ឃើញថា ការផ្សព្វផ្សាយនេះអាចមានឥទ្ធិពលអវិជ្ជមានដល់ភាពជោគជ័យនៃការធ្វើបុនរីតិសម្បទា។ ប្រសិនបើសេចក្ដីណែនាំនេះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ អភិបាលបណ្ដោះអាសន្នត្រូវជូនដំណឹងអំពីសេចក្ដីណែនាំនេះ ដល់ម្ចាស់បំណុលរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដោយបញ្ជាក់នូវប្រភេទ និងរយៈពេលនៃការផ្អាកសងបំណុលជាបណ្ដោះអាសន្ននេះ។

**មាត្រា១៤.-**

ប្រសិនបើអភិបាលបណ្ដោះអាសន្នមិនអាចបញ្ចប់ការអនុវត្តផែនការបុនរីតិសម្បទាបានក្នុងរយៈពេល ៣ (បី) ខែ អគ្គនាយកនៃ **គ.ម.ក.** អាចកំណត់ថា ការធ្វើបុនរីតិសម្បទាមិនអាចប្រព្រឹត្តទៅបាន ហើយអាចណែនាំអភិបាលបណ្ដោះអាសន្នឱ្យទូទាត់ ឬផ្ទេរភ្លាមនូវទ្រព្យសម្បត្តិរបស់អ្នកវិនិយោគសាធារណៈដែលកាន់កាប់ដោយក្រុមហ៊ុន ឬបុគ្គលបោះផ្សាយប្រសិនបើមាន ទៅក្រុមហ៊ុនផ្សេងទៀត ឬអ្នកវិនិយោគសាធារណៈ ។

**មាត្រា១៥.-**

ក្នុងករណីដែលអគ្គនាយកនៃ **គ.ម.ក.** ពិនិត្យឃើញថា អភិបាលបណ្ដោះអាសន្នមិនបានបំពេញការងារតាមកាលបរិច្ឆេទកំណត់ ឬតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** អគ្គនាយកនៃ **គ.ម.ក.** អាច៖

១- ដកអភិបាលបណ្ដោះអាសន្ននោះចេញ និងតែងតាំងអភិបាលបណ្ដោះអាសន្នថ្មីជំនួស ឬ

២- ដកអភិបាលបណ្ដោះអាសន្ននោះចេញ ដោយសម្រេចមិនតែងតាំងអភិបាលបណ្ដោះអាសន្នថ្មីជំនួស។

ក្នុងករណីដែលអគ្គនាយកនៃ **គ.ម.ក.** សម្រេចមិនតែងតាំងអភិបាលបណ្តោះអាសន្នថ្មីជំនួស អគ្គនាយកនៃ **គ.ម.ក.** អាចណែនាំក្រុមហ៊ុន ឬបុគ្គលបោះផ្សាយឱ្យទូទាត់ ឬផ្ទេរភ្លាមនូវទ្រព្យសម្បត្តិរបស់អ្នកវិនិយោគសាធារណៈដែលកាន់កាប់ដោយក្រុមហ៊ុន ឬបុគ្គលបោះផ្សាយប្រសិនបើមាន ទៅក្រុមហ៊ុនផ្សេងទៀត ឬអ្នកវិនិយោគសាធារណៈ ហើយសម្រេចឱ្យជម្រះបញ្ជីក្រៅផ្លូវតុលាការ ឬតាមផ្លូវតុលាការ។

## ផ្នែកទី២
## កិច្ចការពារអ្នកវិនិយោគសាធារណៈ

**មាត្រា១៦ .-**

សាច់ប្រាក់ និងមូលបត្រដែលមាននៅក្នុងគណនីអតិថិជនរបស់ក្រុមហ៊ុន ត្រូវរក្សាទុកដាច់ដោយឡែកពីទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននៅគ្រប់ដំណាក់កាលនៃការធ្វើបុនរីតិសម្បទា។

ក្នុងករណីដែលទ្រព្យសម្បត្តិ និងមូលនិធិនៅក្នុងគណនីអតិថិជនម្នាក់ ឬច្រើននាក់ធ្លាក់ក្រោមកម្រិតអាចផ្គូផ្គងបាន ទ្រព្យសម្បត្តិ និងមូលនិធិដែលនៅសល់ក្នុងគណនីរបស់អតិថិជននោះ ត្រូវបែងចែកឱ្យអតិថិជន ឬផ្ទេរទៅក្រុមហ៊ុនផ្សេងទៀតតាមគោលការណ៍ប៉ារីប៉ាស៊ុយ (Pari Passu)។

ករណីការទូទាត់ត្រូវបានធ្វើឡើងតាមគោលការណ៍ប៉ារីប៉ាស៊ុយក្នុងអំឡុងពេលនៃការអនុវត្តផែនការបុនរីតិសម្បទា ឬពាក់ព័ន្ធនឹងការអនុវត្តផែនការបុនរីតិសម្បទា ការទូទាត់នោះត្រូវបានចាត់ទុកថាមានការយល់ព្រមជាស្វ័យប្រវត្តិពីអតិថិជន ហើយការទូទាត់នេះជាការទូទាត់ទាំងស្រុង និងស្ថាពរចំពោះសិទ្ធិលើបំណុលទាំងអស់របស់អតិថិជន ទោះបីមានបណ្តឹងទាមទារទូទាត់ពីអតិថិជនក៏ដោយ។

## ជំពូកទី៤
## លទ្ធផល និងការបញ្ចប់នីតិវិធីបុនរីតិសម្បទា

**មាត្រា១៧ .-**

អភិបាលបណ្តោះអាសន្នត្រូវរៀបចំ និងដាក់របាយការណ៍ជូន **គ.ម.ក.** តាមកាលបរិច្ឆេទកំណត់ និងជូនទៅបុគ្គលពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

អភិបាលបណ្តោះអាសន្នត្រូវរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការបុនរីតិសម្បទាជាប្រចាំជូន **គ.ម.ក.** ទៅតាមក្របខ័ណ្ឌពេលវេលាដូចមាននៅក្នុងផែនការបុនរីតិសម្បទា ឬតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

អភិបាលបណ្តោះអាសន្នត្រូវរៀបចំរបាយការណ៍វាយតម្លៃស្ថាពរដាក់ជូន **គ.ម.ក.** ភ្លាម នៅចុងបញ្ចប់នៃការអនុវត្តផែនការបុនរីតិសម្បទាក្នុងរយៈពេល ៣ (បី) ខែចាប់ពីកាលបរិច្ឆេទតែងតាំងអភិបាលបណ្តោះ-អាសន្ន ដោយបញ្ជាក់អំពីស្ថានភាពថា តើក្រុមហ៊ុន ឬបុគ្គលបោះផ្សាយសាធនីយ អាចសាធនីយ ឬអសាធនីយ។ អភិបាលបណ្តោះអាសន្នអាចផ្តល់របាយការណ៍វាយតម្លៃស្ថាពរជូន **គ.ម.ក.** បាន នៅមុនពេលបញ្ចប់ការអនុវត្តផែនការបុនរីតិសម្បទា។

**មាត្រា១៨ .-**

ក្នុងករណីដែលអភិបាលបណ្តោះអាសន្នវាយតម្លៃជាស្ថាពរថាក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ស្ថិតក្នុង

ស្ថានភាពសាធនីយ អភិបាលបណ្ដោះអាសន្នត្រូវស្នើសុំមកអគ្គនាយកនៃ **គ.ម.ក.** ដើម្បីពិនិត្យ និងសម្រេចដក វិធានការបុនឧីតិសម្បទា។

**មាត្រា១៩ .-**

ក្នុងករណីដែលអភិបាលបណ្ដោះអាសន្នវាយតម្លៃជាស្ថាពរក្នុងរយៈពេល ៣ (បី) ខែ នៃការអនុវត្ត ផែនការបុនឧីតិសម្បទាថា ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយស្ថិតក្នុងស្ថានភាពអាចសាធនីយ ក្រុមហ៊ុន ឬបុគ្គល បោះផ្សាយត្រូវបានអនុញ្ញាតឱ្យបន្តអនុវត្តផែនការបុនឧីតិសម្បទា ក្នុងរយៈពេលយ៉ាងយូរ ៣(បី) ខែ ទៀត។ ប៉ុន្តែប្រសិនបើក្នុងរយៈពេលបន្ត ៣(បី) ខែនេះ ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ មិនអាចអនុវត្តតាមច្បាប់ និងវិធាន ប្រុងប្រយ័ត្នបានទេ ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយត្រូវបន្តនីតិវិធីជម្រះបញ្ជីក្រៅប្រព័ន្ធតុលាការ ដែលកំណត់ ដោយ **គ.ម.ក.**។ ក្នុងករណីនេះ អ្នកជម្រះបញ្ជីត្រូវបានជ្រើសរើស និងតែងតាំងដោយ អគ្គនាយកនៃ **គ.ម.ក.** ចេញពីបញ្ជីដែលទទួលស្គាល់ពី **គ.ម.ក.**។ អភិបាលបណ្ដោះអាសន្នរបស់ក្រុមហ៊ុន ឬបុគ្គលបោះ-ផ្សាយអាចត្រូវបានតែងតាំងជាអ្នកជម្រះបញ្ជីផងដែរ។ អ្នកជម្រះបញ្ជីត្រូវជម្រះទ្រព្យសកម្ម និងសងបំណុលនៃ ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ក្រោមការត្រួតពិនិត្យរបស់ **គ.ម.ក.**។

**មាត្រា២០ .-**

ក្នុងករណីដែលអភិបាលបណ្ដោះអាសន្នវាយតម្លៃជាស្ថាពរថា ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយស្ថិតក្នុង ស្ថានភាពអសាធនីយ អគ្គនាយកនៃ **គ.ម.ក.** សម្រេចឱ្យអភិបាលបណ្ដោះអាសន្ន ទូទាត់ ឬផ្ទេរភ្លាមនូវ ទ្រព្យសម្បត្តិរបស់អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ដោយក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ប្រសិនបើមាន ទៅក្រុមហ៊ុនផ្សេងទៀត ឬអ្នកវិនិយោគសាធារណៈ រួចប្ដឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីជម្រះបញ្ជី។ ក្នុងករណីនេះ អគ្គនាយកនៃ **គ.ម.ក.** អាចស្នើសុំទៅតុលាការ ដើម្បីតែងតាំងអភិបាលបណ្ដោះអាសន្នជា អ្នកជម្រះបញ្ជី ឬតែងតាំងអ្នកជម្រះបញ្ជីចេញពីបញ្ជីដែលទទួលស្គាល់ពី **គ.ម.ក.**។

## ជំពូកទី៥
## ការជម្រះបញ្ជីដោយស្ម័គ្រចិត្ត

**មាត្រា២១ .-**

ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ដែលសាធនីយ អាចស្នើសុំជម្រះបញ្ជីដោយស្ម័គ្រចិត្តបាន ក្នុងករណី ណាមួយដូចខាងក្រោម÷

ក- ការដល់អាយុកាលរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ។

ខ- សេចក្ដីសម្រេចរបស់មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញរបស់ភាគហ៊ុនិក ដោយអនុលោមតាម លក្ខន្តិកៈរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ឬតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា២២ .-**

អភិបាលក្រុមហ៊ុន ឬភាគហ៊ុនិកម្នាក់ដែលមានសិទ្ធិបោះឆ្នោត អាចស្នើឱ្យមានការជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ដោយស្ម័គ្រចិត្ត នៅពេលមហាសន្និបាតភាគហ៊ុនិក។

**មាត្រា២៣ .-**

លិខិតកោះអញ្ជើញស្ដីពីការប្រជុំរបស់ភាគហ៊ុនិក ក្នុងគោលបំណងជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះ-

ផ្សាយដោយស្ម័គ្រចិត្តដែលស្នើឡើង ត្រូវចែងពីលក្ខខណ្ឌសម្រាប់ការជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយនោះ។

**មាត្រា២៤ .-**

ក្រោយពីទទួលបានសេចក្ដីសម្រេចរបស់ភាគហ៊ុនិកស្ដីពីការជម្រះបញ្ជីដោយស្ម័គ្រចិត្ត ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយត្រូវដាក់ពាក្យស្នើសុំជម្រះបញ្ជីនោះជូនមក **គ.ម.ក.**។

**មាត្រា២៥ .-**

ក្រោយពីទទួលបានពាក្យស្នើសុំជម្រះបញ្ជីដោយស្ម័គ្រចិត្តរួច អគ្គនាយកនៃ **គ.ម.ក.** ត្រូវចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យជម្រះបញ្ជីដោយស្ម័គ្រចិត្តជូនក្រុមហ៊ុន ឬបុគ្គលបោះផ្សាយនោះ បន្ទាប់ពីបានពិនិត្យឃើញថាមានសាធនភាពគ្រប់គ្រាន់ និងមានមូលហេតុសមស្រប។

**មាត្រា២៦ .-**

បន្ទាប់ពីបានទទួលសេចក្ដីសម្រេចអនុញ្ញាតឱ្យជម្រះបញ្ជី ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយត្រូវបញ្ឈប់ប្រតិបត្តិការរបស់ខ្លួនភ្លាម និងត្រូវទូទាត់ ឬផ្ទេរភ្លាមនូវសាច់ប្រាក់ ឬមូលបត្រដែលមាននៅក្នុងគណនីអតិថិជនដែលកាន់កាប់ដោយក្រុមហ៊ុន ប្រសិនបើមាន ទៅក្រុមហ៊ុនផ្សេងទៀត ឬអ្នកវិនិយោគសាធារណៈ ឱ្យបានមុនការជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដោយស្ម័គ្រចិត្ត។

**មាត្រា២៧ .-**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវតែងតាំងដោយផ្ទាល់ ឬតាមសំណើរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ នូវអ្នកជម្រះបញ្ជីដែលមានវិជ្ជាជីវៈប្រកបដោយគុណវុឌ្ឍិចេញពីបញ្ជីឈ្មោះអភិបាលបណ្ដោះអាសន្ននិងអ្នកជម្រះ-បញ្ជីដែលទទួលស្គាល់ពី **គ.ម.ក.**។

**មាត្រា២៨ .-**

អ្នកជម្រះបញ្ជីមានសិទ្ធិអំណាច និងភារកិច្ចដូចខាងក្រោម÷

១- ធ្វើជាតំណាងពេញច្បាប់ឱ្យក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ក្នុងការដឹកនាំ និងគ្រប់គ្រងបន្តដោយផ្ដាច់មុខរហូតដល់ការជម្រះបញ្ជីត្រូវបានបញ្ចប់។

២- រៀបចំឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ដើម្បីធានាឱ្យមាននូវស្ថានភាពពិតនៃគណនីពាក់ព័ន្ធនីមួយៗ ធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ការជម្រះបញ្ជីនោះ។

៣- ផ្ទៀងផ្ទាត់ឡើងវិញនូវអត្ថិភាពចលនទ្រព្យ និងអចលនទ្រព្យ តាមបញ្ជីសារពើភណ្ឌ និងចាត់វិធានការថែរក្សាទ្រព្យសម្បត្តិទាំងនោះឱ្យបានគង់វង្ស ដើម្បីធានាសមភាពឱ្យភាគហ៊ុនិក និងម្ចាស់បំណុល។

៤- ចេញសេចក្ដីប្រកាសជូនដំណឹងជាសាធារណៈពីការជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដោយដាក់ឱសានវាទឱ្យម្ចាស់បំណុលម្នាក់ៗផ្ដល់ឯកសារសំណាងនៃឥណទេយ្យរបស់ខ្លួន ហើយប្រសិនបើម្ចាស់បំណុលណាមិនបានផ្ដល់ទាន់ពេលកំណត់នោះ ម្ចាស់បំណុលនោះត្រូវបាត់សិទ្ធិទាមទារបំណុល។

៥- កោះប្រជុំភាគហ៊ុនិកទាំងអស់ និងបុគ្គលពាក់ព័ន្ធ ក្នុងករណីមានការសម្រេចទទួលយក និងធ្វើអាជីវកម្មបន្តនូវក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដែលជាកម្មវត្ថុនៃការជម្រះបញ្ជី ដើម្បីឱ្យធ្វើសេចក្ដីសម្រេចឯកភាពគ្នាជាគោលការណ៍ពីកិច្ចការនោះ។

៦- ចេញសេចក្តីប្រកាសបដិសេធចំពោះកិច្ចព្រមព្រៀង ឬលិខិតស្នាមទាំងឡាយណាដែលក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ បានធ្វើឡើងដោយមិនប្រក្រតី ឬមិនស្របច្បាប់ នៅមុនពេលចាប់ផ្តើមនីតិវិធីជម្រះបញ្ជី។

៧- រៀបចំបញ្ជីរាយនាមកូនបំណុលទាំងអស់ជាមួយនឹងទឹកប្រាក់ដែលនៅជំពាក់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ដោយរាប់បញ្ចូលទាំងភាគហ៊ុនិកផងដែរ ប្រសិនបើមាន ហើយទាមទារបំណុលទាំងនោះតាមគ្រប់វិធី ទោះមិនទាន់ដល់កាលកំណត់ក្តី។

៨- រៀបចំបញ្ជីរាយនាមម្ចាស់បំណុលទាំងអស់ដែលត្រូវបានទទួលស្គាល់ ជាមួយនឹងទឹកប្រាក់ដែលត្រូវទូទាត់សង ដោយរាប់បញ្ចូលទាំងប្រាក់ពន្ធដារដែលនៅជំពាក់រដ្ឋ និងប្រាក់បៀវត្សរបស់កម្មករនិយោជិត តាមច្បាប់ជាធរមាន។

៩- ជម្រះទ្រព្យសកម្មរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ តាមការលក់ចេញ ឬតាមវិធីផ្សេងទៀត។

១០- ជម្រះទ្រព្យអកម្មរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ តាមការទូទាត់សងបំណុលទៅតាមលទ្ធភាពជាក់ស្តែង ដោយអនុវត្តតាមអាទិភាព ដូចមានចែងនៅក្នុងមាត្រា ៣៤ នៃអនុក្រឹត្យនេះ។

១១- រៀបចំតារាងតុល្យការនៃការជម្រះបញ្ជី បែងចែកទឹកប្រាក់ជាលទ្ធផលនៃការជម្រះបញ្ជីឱ្យភាគហ៊ុនិក និងជម្រះគណនីពាក់ព័ន្ធទាំងអស់ទុកជាការបញ្ចប់ការជម្រះបញ្ជីជាស្ថាពរ។

១២- តួនាទី និងភារកិច្ចផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

ការអនុវត្តសិទ្ធិអំណាច និងភារកិច្ចរបស់អ្នកជម្រះបញ្ជីត្រូវស្ថិតនៅក្រោមការតាមដាន និងការត្រួតពិនិត្យរបស់ **គ.ម.ក.**។

**មាត្រា២៩ ..**

អ្នកជម្រះបញ្ជីត្រូវអនុវត្តនីតិវិធីក្នុងការជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដោយស្ម័គ្រចិត្តដូចខាងក្រោម÷

១- ចុះផ្សាយលិខិតជូនដំណឹងស្តីពីការជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយជាបន្ទាន់ សម្រាប់រយៈពេល ២(ពីរ) សប្តាហ៍ជាប់ៗគ្នា នៅក្នុងសារព័ត៌មានដែលបោះផ្សាយ ឬចែកចាយនៅក្នុងកន្លែងដែលក្រុមហ៊ុន ឬបុគ្គលបោះផ្សាយមានទីស្នាក់ការចុះបញ្ជីពិតប្រាកដ។

២- កោះប្រជុំជាមួយភាគហ៊ុនិក កូនបំណុល និងម្ចាស់បំណុលដោយឡែក ឬរួមគ្នាតាមការចាំបាច់។

៣- ធ្វើរបាយការណ៍ជូន **គ.ម.ក.** នៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃយ៉ាងយូរបំផុត គិតពីថ្ងៃបញ្ចប់កិច្ចប្រជុំចុងក្រោយខាងលើ ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុនៃអង្គប្រជុំទាំងនោះ បញ្ជីរាយនាមនៃកូនបំណុល បញ្ជីរាយនាមនៃម្ចាស់បំណុលដែលមានការទទួលស្គាល់ និងបញ្ជីទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដែលជាកម្មវត្ថុនៃការជម្រះបញ្ជីនោះ។

បន្ទាប់ពីទទួលបានសេចក្តីសម្រេចឯកភាពពី **គ.ម.ក.** អ្នកជម្រះបញ្ជីអាចអនុវត្តភារកិច្ចរបស់ខ្លួនរហូតដល់ចប់ការជម្រះបញ្ជីទាំងស្រុង។

៤- ដាក់ជូន **គ.ម.ក.** នៅក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃយ៉ាងយូរបំផុត គិតពីថ្ងៃបញ្ចប់ការជម្រះបញ្ជីនូវរបាយការណ៍ស្តីពីលទ្ធផលនៃការជម្រះបញ្ជី និងសេចក្តីប្រកាសពីការបញ្ចប់ការជម្រះបញ្ជីនោះជាស្ថាពរ។

**មាត្រា៣០ .-**

**គ.ម.ភ.** អាចដកហូតអាជ្ញាបណ្ណ ការអនុញ្ញាត ឬការទទួលស្គាល់ពីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយមកវិញយ៉ាងយូរបំផុតដល់ទទួលបានសេចក្ដីប្រកាសស្ដីពីការបញ្ចប់ការជម្រះបញ្ជីដោយស្ម័គ្រចិត្ត។

**មាត្រា៣១ .-**

ក្រោយពេលដែលការជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដោយស្ម័គ្រចិត្ត ត្រូវបានបញ្ចប់ អ្នកជម្រះបញ្ជីត្រូវធ្វើសេចក្ដីប្រកាសពីការរំលាយក្រុមហ៊ុន ឬបុគ្គលបោះផ្សាយនោះ ទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ប្រសិនបើមានសំណើសុំរំលាយក្រុមហ៊ុនពីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ។

នៅពេលទទួលបានសេចក្ដីប្រកាសពីការរំលាយក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន ឬបុគ្គលបោះផ្សាយនោះតាមនីតិវិធីច្បាប់ជាធរមាន។

**មាត្រា៣២ .-**

នៅក្នុងរយៈពេលនៃការជម្រះបញ្ជីដោយស្ម័គ្រចិត្តរបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ក្នុងករណីចាំបាច់ អគ្គនាយកនៃ **គ.ម.ភ.** អាចស្នើសុំទៅតុលាការ ដើម្បីឱ្យដាក់ការជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដោយស្ម័គ្រចិត្តក្រោមការត្រួតពិនិត្យពីតុលាការ។

**មាត្រា៣៣ .-**

ប្រសិនបើសកម្មភាពរបស់អ្នកជម្រះបញ្ជីត្រូវបានរារាំង ជ្រៀតជ្រែក ឬបង្អាក់ដោយក្រុមហ៊ុន ឬបុគ្គលបោះផ្សាយអ្នកជម្រះបញ្ជីអាចប្រើប្រាស់សិទ្ធិប្ដឹងទៅតុលាការ បន្ទាប់ពីបានរាយការណ៍ជូន **គ.ម.ភ.**។

## ជំពូកទី៦
## លំដាប់អាទិភាពនៃការសងបំណុល

**មាត្រា៣៤ .-**

ប្រាក់ដែលទទួលបានពីការជម្រះបញ្ជីទ្រព្យសម្បត្តិកូនបំណុល ត្រូវប្រើប្រាស់សម្រាប់ទូទាត់តាមលំដាប់ដូចខាងក្រោមនេះ÷

១- លាភការ និងសោហ៊ុយចំណាយផ្សេងៗ ដែលពាក់ព័ន្ធនឹងអភិបាលបណ្ដោះអាសន្ន និងការជម្រះ-បញ្ជី។

២- ប្រាក់បៀវត្សបុគ្គលិក និងកម្មករនិយោជិត សេវារដ្ឋបាល ប្រាក់ប្រដាប់ក្ដី និងពន្ធផ្សេងៗទៀតរបស់តុលាការ។

៣- បណ្ដឹងទាមទាររបស់ម្ចាស់បំណុលមានកិច្ចធានា។

៤- ពន្ធដាររបស់រដ្ឋ និងពិន័យតាមការអនុវត្តសេចក្ដីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច។

៥- បណ្ដឹងទាមទារគ្មានកិច្ចធានាទាំងអស់ដែលបានទទួលស្គាល់។

## ជំពូកទី៧
## បទប្បញ្ញត្តិរួម

**មាត្រា៣៥ .-**

ក្នុងអំឡុងពេលបំពេញតួនាទី និងភារកិច្ច អភិបាលបណ្ដោះអាសន្ន និងអ្នកជម្រះបញ្ជី ត្រូវប្ដឹងទៅ

តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ប្រសិនបើពិនិត្យឃើញថាមានបទល្មើសព្រហ្មទណ្ឌ។

**មាត្រា៣៦ .-**

មន្ត្រី **គ.ម.ក**. អភិបាលបណ្តោះអាសន្ន បុគ្គលិករបស់អភិបាលបណ្តោះអាសន្ន អ្នកជម្រះបញ្ជី និង បុគ្គលិករបស់អ្នកជម្រះបញ្ជី ត្រូវរួចផុតពីការទទួលខុសត្រូវទាំងអស់នៅក្នុងការអនុវត្តតួនាទី ភារកិច្ច និង សិទ្ធិអំណាចដោយសុចរិតផ្អែកតាមភាពស្មោះត្រង់ និងគ្មានការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងអនុក្រឹត្យ នេះ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣៧ .-**

សោហ៊ុយ និងចំណាយផ្សេងៗសម្រាប់ការធ្វើបុនរីតិសម្បទា អភិបាលបណ្តោះអាសន្ន ការជម្រះបញ្ជី ត្រូវស្ថិតក្នុងតម្លៃសមស្រប និងជាបន្ទុករបស់ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ។

សោហ៊ុយ និងចំណាយផ្សេងៗត្រូវគិតលើមូលដ្ឋាននៃអត្រាតម្លៃវិជ្ជាជីវៈប្រចាំតំបន់ជាធរមាន ឬតាម ការកំណត់របស់ **គ.ម.ក**.។

រាល់ទ្រព្យសម្បត្តិ និង/ឬមូលនិធិដែលកាន់កាប់ដោយក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ ដែលជាកម្មសិទ្ធិ របស់អ្នកវិនិយោគសាធារណៈ មិនត្រូវបានប្រើប្រាស់សម្រាប់ទូទាត់សោហ៊ុយ និងចំណាយសម្រាប់បុនរីតិ-សម្បទា អភិបាលបណ្តោះអាសន្ន និងការជម្រះបញ្ជីឡើយ។

**មាត្រា៣៨ .-**

លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក**. ឬតុលាការ ផែនការបុនរីតិសម្បទា និង/ឬ របាយការណ៍របស់អភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជីដែលត្រូវបានតែងតាំងអនុលោមតាមអនុក្រឹត្យ នេះ មិនត្រូវផ្សព្វផ្សាយឡើយ។

ការហាមឃាត់មិនឱ្យផ្សព្វផ្សាយព័ត៌មានដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មិនត្រូវរាប់ បញ្ចូលនូវព័ត៌មានដែលផ្សព្វផ្សាយក្នុងគោលបំណងដូចខាងក្រោម÷

១- ព័ត៌មានអំពីការកសាងសំណុំរឿង និងនីតិវិធីតុលាការ។

២- ព័ត៌មានអំពីការអនុញ្ញាត ឬជួយដល់ **គ.ម.ក**. ក្នុងការអនុវត្តសិទ្ធិអំណាចដែលប្រគល់ជូនដើម្បី បំពេញកិច្ចការពាក់ព័ន្ធនឹងក្ស័យធន។

៣- ព័ត៌មានអំពីការអនុញ្ញាត ឬជួយដល់ប្រតិបត្តិករទីផ្សារមូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ក្នុងការបំពេញមុខងាររបស់ខ្លួន។

៤- ព័ត៌មានអំពីការអនុញ្ញាត ឬជួយដល់ស្ថាប័នរដ្ឋណាមួយ ក្នុងការបំពេញមុខងាររបស់ខ្លួនតាមច្បាប់។

៥- ព័ត៌មានអំពីការអនុញ្ញាត ឬជួយដល់តុលាការបំពេញមុខងារតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីក្ស័យធន ឬ

៦- ព័ត៌មានអំពីការអនុញ្ញាត ឬជួយដល់និយ័តករមូលបត្របរទេសដែលបំពេញតួនាទីប្រហាក់ប្រហែល ទៅនឹង **គ.ម.ក**. ក្នុងការអនុវត្តតួនាទីត្រួតពិនិត្យ និងគ្រប់គ្រងក្នុងវិស័យមូលបត្រ។

៧- ព័ត៌មានផ្សេងទៀតដែលអនុញ្ញាតដោយ **គ.ម.ក**. ឬស្ថាប័នមានសមត្ថកិច្ច និងបទប្បញ្ញត្តិជា ធរមាន។

**មាត្រា៣៩ ._**

**គ.ម.ភ.** អាចចេញគោលការណ៍ណែនាំដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃច្បាប់ និងលក្ខខណ្ឌនៃអនុក្រឹត្យនេះដល់សាធារណជន និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ។

## ជំពូកទី៨
## ទោសប្បញ្ញត្តិ

**មាត្រា៤០ ._**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះមាន ទណ្ឌកម្មរដ្ឋបាល និងពិន័យអន្តរការណ៍ ដែលជាសមត្ថកិច្ចរបស់អគ្គនាយកនៃ **គ.ម.ភ.**។

ទណ្ឌកម្មរដ្ឋបាលអាចជា÷

១- ការព្រមានជាលាយលក្ខណ៍អក្សរ។

២- ការដឹកនាំកែតម្រង់។

៣- ការព្យួរការទទួលស្គាល់។

៤- ការលុបឈ្មោះចេញពីបញ្ជីដែលទទួលស្គាល់ពី **គ.ម.ភ.**។

នីតិវិធី និងកម្រិតនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់ **គ.ម.ភ.**។

**មាត្រា៤១ ._**

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរលត់បណ្តឹងអាជ្ញា។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ អគ្គនាយកនៃ **គ.ម.ភ.** ត្រូវកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការតាមនីតិវិធី។

**មាត្រា៤២ ._**

អភិបាលបណ្តោះអាសន្ន ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដែលមិនគោរពតាមកថាខណ្ឌទី១ នៃមាត្រា១២ នៃអនុក្រឹត្យនេះ ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាល។

**មាត្រា៤៣ ._**

អភិបាលបណ្តោះអាសន្នដែលមិនបានរក្សាទុកសាច់ប្រាក់ ឬមូលបត្រដែលមាននៅក្នុងគណនីអតិថិជនរបស់ក្រុមហ៊ុនដាច់ដោយឡែកពីទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន នៅគ្រប់ដំណាក់កាលនៃការធ្វើបុននីតិសម្បទា និងមិនបានធ្វើការបែងចែកទ្រព្យសម្បត្តិ និងមូលនិធិដែលនៅសល់ក្នុងគណនីរបស់អតិថិជន តាមគោលការណ៍ប៉ារីប៉ាស៊ុយ ក្នុងករណីដែលទ្រព្យសម្បត្តិ និងមូលនិធិក្នុងគណនីអតិថិជនម្នាក់ ឬច្រើននាក់ធ្លាក់ក្រោមកម្រិតអាចផ្ទេរបាន ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាល។

ក្នុងករណីដែលទទួលរងនូវទណ្ឌកម្មរដ្ឋបាលម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដដែល ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល។

**មាត្រា៤៤ ._**

ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដែលមិនបញ្ឈប់ប្រតិបត្តិការរបស់ខ្លួនបន្ទាប់ពីបានទទួលសេចក្តីសម្រេច

អនុញ្ញាតឱ្យជម្រះបញ្ជី ឬមិនបានទូទាត់ ឬផ្ទេរនូវសាច់ប្រាក់ ឬមូលបត្រដែលមាននៅក្នុងគណនីអតិថិជនដែលកាន់កាប់ដោយក្រុមហ៊ុន ប្រសិនបើមាន ទៅក្រុមហ៊ុនផ្សេងទៀត ឬអ្នកវិនិយោគសាធារណៈឱ្យបានមុនការជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយដោយស្ម័គ្រចិត្ត ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៥០០.០០០.០០០ (ប្រាំរយលាន) រៀល។

**មាត្រា៤៥ ._**

អ្នកជម្រះបញ្ជីដែលខកខានមិនបានចុះផ្សាយលិខិតជូនដំណឹងស្តីពីការជម្រះបញ្ជីក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ សម្រាប់រយៈពេល ២ (ពីរ) សប្តាហ៍ជាប់ៗគ្នា នៅក្នុងសារព័ត៌មានដែលបោះផ្សាយ ឬចែកចាយនៅក្នុងកន្លែងដែលក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ មានទីស្នាក់ការចុះបញ្ជីពិតប្រាកដ ហើយបណ្តាលឱ្យមានការខូចខាតប្រយោជន៍ដល់ម្ចាស់បំណុល ឬបុគ្គលពាក់ព័ន្ធ ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាល។

ក្នុងករណីដែលទទួលរងនូវទណ្ឌកម្មរដ្ឋបាលម្តងរួចហើយ នៅតែបន្តប្រព្រឹត្តល្មើសដដែល ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល។

**មាត្រា៤៦ ._**

អ្នកជម្រះបញ្ជីដែលមិនបានដាក់របាយការណ៍ជូន **គ.ម.ក.** តាមរយៈពេលកំណត់ដូចមានចែងក្នុងចំណុចទី ៣ ឬទី ៤ នៃមាត្រា ២៩ នៃអនុក្រឹត្យនេះ ត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាល។

**មាត្រា៤៧ ._**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀត បុគ្គលដែលផ្សព្វផ្សាយផែនការបុននីតិសម្បទា និង/ ឬរបាយការណ៍របស់អភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជីដោយគ្មានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** និងមិនមានមូលហេតុដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣៨ ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល។

**មាត្រា៤៨ ._**

បុគ្គលណាដែលរារាំង ឬជ្រៀតជ្រែកដល់ការអនុវត្តតួនាទី និងភារកិច្ចរបស់អភិបាលបណ្តោះអាសន្ន ឬអ្នកជម្រះបញ្ជី ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០០.០០០.០០០ (មួយរយលាន) រៀល។

**មាត្រា៤៩ ._**

នាយក អ្នកគ្រប់គ្រង ក្រុមហ៊ុន ឬបុគ្គលបោះផ្សាយ អភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជីដែលប្រព្រឹត្តអំពើរំលោភអំណាចក្នុងការបំពេញមុខងាររបស់ខ្លួន ឬរំលោភបំពានបញ្ញត្តិហាមឃាត់នៃអនុក្រឹត្យនេះ ឬបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងអនុក្រឹត្យនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០០.០០០.០០០ (មួយរយលាន) រៀល។

**មាត្រា៥០ ._**

ការអនុវត្តទណ្ឌកម្មដូចមានកំណត់ក្នុងអនុក្រឹត្យនេះ មិនរារាំងដល់ការអនុវត្តទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៥១.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៥២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៣ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ